# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងសុខាភិបាល

លេខ : ៣២៣/៧៥៤ ប្រក.កសក/សខភប

# ប្រកាសរួម
## ស្តីពី
## ការគ្រប់គ្រងផលិតកម្ម អាហរណ នីហរណកម្ម និង ពាណិជ្ជកម្មបសុឱសថ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង រដ្ឋមន្ត្រីក្រសួងសុខាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០២ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងឱសថ

-បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល

-បានឃើញអនុក្រឹត្យលេខ ៦៩ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៨ ស្តីពី បមាណី និង ការគ្រប់គ្រងសម្ភារៈកសិកម្ម

-បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០០ ស្តីពីការចាត់ថ្នាក់ជាតិពុលសម្រាប់វិស័យសុខាភិបាល

-បានឃើញប្រកាសរួមលេខ ០២ ប្រក.កយ.កសក/០៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០៤ ស្តីពីការដាក់ឱ្យប្រើប្រាស់គំរូសំណុំលិខិតដោះស្រាយបទល្មើសបមាណីគុណភាពសម្ភារៈកសិកម្ម ដល់មន្ត្រីនគរបាលយុត្តិធម៌របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ក្រសួងសុខាភិបាល



Downloaded from http://www.khmerlaws.com

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១** : ប្រកាសរួមនេះកំណត់ក្របខណ្ឌនៃការគ្រប់គ្រងផលិតកម្ម អាហរ័ណ នីហរ័ណកម្ម និង ពាណិជ្ជកម្មបសុឱសថ នៅក្នុងព្រះរាជាណាចក្រកម្ពុជា សំដៅលុបបំបាត់ការធ្វើអាជីវកម្មបសុឱសថអនាធិបតេយ្យ ធានាគុណភាពបសុឱសថ និង ការពារផលប្រយោជន៍អ្នកប្រើប្រាស់ ផលិតករ និង ពាណិជ្ជករ ។

**ប្រការ ២** : បសុឱសថ សំដៅដល់សារជាតិមួយមុខ ឬ ច្រើនមុខ ក្រោមទំរង់ជាអាទិ៍ ជាតិគីមី ជីវផលិតផល ជាតិអតិសុខុមប្រាណ សេរ៉ូម វ៉ាក់សាំង និង រូបធាតុរុក្ខជាតិដែលលាយផ្សំឡើងសម្រាប់ :

-ប្រើប្រាស់ក្នុងការបង្ការ ឬ ព្យាបាលជំងឺសត្វ

-ធ្វើរោគវិនិច្ឆ័យសម្រាប់វិស័យបសុព្យាបាល

-កែប្រែ ឬ ទ្រទ្រង់មុខងារនៃសរីរាង្គសត្វ ។

**ប្រការ ៣** : រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលបាន និង កំពុង ឬ មានបំណងធ្វើអាជីវកម្មផលិតកម្ម អាហរ័ណ នីហរណកម្ម ចែកចាយ ឬ លក់ដូរបសុឱសថ ត្រូវមានលិខិតអនុញ្ញាតធ្វើអាជីវកម្ម ចុះទិដ្ឋាការ ឬ បញ្ជិកា និងលិខិតអនុញ្ញាតនាំចូលពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

## ជំពូកទី ២

## បែបបទ និង លក្ខខណ្ឌនៃការបើកគ្រឹះស្ថានផលិតបសុឱសថ

**ប្រការ ៤** : រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលមានបំណង ឬ កំពុងបើកគ្រឹះស្ថានផលិតបសុឱសថ ត្រូវមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

**ប្រការ ៥** : រូបវន្តបុគ្គល ឬ នីតិបុគ្គល អាចមានសិទ្ធិបើកគ្រឹះស្ថានផលិតបសុឱសថ ត្រូវមានលក្ខណៈសម្បត្តិ ដូចខាងក្រោម :

-មានបរិញ្ញាប័ត្របសុព្យាបាលដែលទទួលស្គាល់ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-មានសញ្ញាប័ត្រឱសថការីឧត្តម ដែលទទួលស្គាល់ពីក្រសួងសុខាភិបាល

-មានទីលំនៅបច្ចុប្បន្ន ឬ ទីស្នាក់ការនៅក្នុងព្រះរាជាណាចក្រកម្ពុជា

-មិនដែលមានទោសពីបទឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ ។

**ប្រការ ៦** : សុំណុំលិខិតសុំបើកគ្រឹះស្ថានផលិតបសុឱសថមាន :

| | |
|---|---|
| -ពាក្យសុំបើកមានបិទតែមប្រើប្រាំរយ(៥០០) រៀល ( មានគំរូ ) | ចំនួន ០២ ច្បាប់ |
| -អង្គការលេខនៃគ្រឹះស្ថានផលិតបសុឱសថច្បាស់លាស់ | ចំនួន ០២ ច្បាប់ |
| -បរិញ្ញាប័ត្របសុព្យាបាល ដែលទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | ចំនួន ០២ ច្បាប់ |
| -មានសញ្ញាប័ត្រឱសថការីឧត្តម ដែលទទួលស្គាល់ពីក្រសួងសុខាភិបាល | ចំនួន ០២ ច្បាប់ |
| -ប្រវត្តិរូបសង្ខេបមានបិទរូបថត ៤ x ៦ របស់អ្នកស្នើសុំ ( មានគំរូ) | ចំនួន ០២ ច្បាប់ |
| -អត្តសញ្ញាណប័ណ្ណរបស់អ្នកស្នើសុំ ( ថតចម្លង ) | ចំនួន ០២ ច្បាប់ |

Downloaded from http://www.khmerlaws.com

-កិច្ចសន្យានៃការធ្វើអាជីវកម្ម( មានគំរូ) ចំនួន ០២ ច្បាប់
-វិញ្ញាបនបត្រសុខភាព ចេញដោយក្រសួងសុខាភិបាល ចំនួន ០២ ច្បាប់
-វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ចេញដោយក្រសួងពាណិជ្ជកម្ម ចំនួន ០២ ច្បាប់
-បញ្ជីដើម ពាណិជ្ជសញ្ញា សេវាសញ្ញា ពាណិជ្ជនាម ឬ លិខិតផ្ទេរសិទ្ធរបស់ក្រុមហ៊ុនផលិត (បើសិនជាមាន ) ចំនួន ០២ ច្បាប់
-លិខិតបញ្ជាក់លើទីតាំងធ្វើអាជីវកម្មចេញដោយអាជ្ញាធរដែនដី ចំនួន ០២ ច្បាប់
-គំនូសបំព្រួញ រូបថត ទីតាំង ចំនួន ០២ ច្បាប់
-គំនូសប្លង់នៃបន្ទប់ផលិតតាមខ្សែចង្វាក់ផលិតកម្ម ចំនួន ០២ ច្បាប់
-បញ្ជីរាយឈ្មោះសម្ភារៈ ឧបករណ៍ បម្រើការផលិត ចំនួន ០២ ច្បាប់
-បញ្ជីរាយឈ្មោះបសុឱសថគ្រោងផលិត ចំនួន ០២ ច្បាប់ ។

សាមីជនត្រូវមកទំនាក់ទំនងដើម្បីបំពេញសំណុំលិខិតខាងលើ នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

**ប្រការ ៧** : ការសុំបើកសាខាផលិតបសុឱសថ ត្រូវអនុវត្តតាមបែបបទ និង លក្ខខណ្ឌដូចគ្នានឹងការសុំបើកគ្រឹះស្ថានផលិតបសុឱសថ ដូចមានចែងក្នុងជំពូកទី ២ នៃប្រកាសរួមនេះដែរ ។

**ប្រការ ៨** : គ្រឹះស្ថានផលិតបសុឱសថ ត្រូវរៀបចំសមស្របតាមលក្ខខណ្ឌបច្ចេកទេសក្នុងផលិតកម្មបសុឱសថ ចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

**ប្រការ ៩** : វិធានសម្រាប់ផលិតកម្មបសុឱសថ រួមមាន :

១- គ្រប់សកម្មភាពផលិតបសុឱសថ ត្រូវឋិតនៅក្រោមការត្រួតពិនិត្យ និង ការទទួលខុសត្រូវរួមរបស់បសុពេទ្យ និងឱសថការីមួយរូប ឬ ច្រើនរូប ដែលមានការចាត់តាំងច្បាស់លាស់ក្នុងអង្គការលេខនៃគ្រឹះស្ថានផលិតបសុឱសថ ។
២-ផលិតកម្មបសុឱសថត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស ។
៣-បសុឱសថត្រូវមានគុណភាពនិងសុវត្ថិភាពត្រឹមត្រូវតាមឯកសារបសុឱសថ ដែលបានតំកល់នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។
៤-បសុឱសថដែលផលិតបានត្រូវមានលេខទិដ្ឋាការចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
៥-គ្រឹះស្ថានផលិតបសុឱសថព្រមទាំងសាខាផលិត ត្រូវធានាចំពោះគុណភាព និង សុវត្ថិភាពបសុឱសថរបស់ខ្លួនដែលបានលក់ជូនអតិថិជន ។ ក្នុងករណីមានបាតុភាពកើតឡើង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ មានសិទ្ធិបញ្ជាឱ្យគ្រឹះស្ថានផ្អាកការផលិត និងប្រមូលបសុឱសថមិនត្រឹមត្រូវទាំងអស់នោះវិញ ។
៦-បសុឱសថដែលផលិតត្រូវមានការវេចខ្ចប់សមស្របតាមលក្ខខណ្ឌបច្ចេកទេស ។

**ប្រការ ១០** : ក្នុងករណីអវត្តមានបសុពេទ្យ ឬឱសថការីទទួលខុសត្រូវ គ្រឹះស្ថានផលិតបសុឱសថត្រូវមានបសុពេទ្យ ឬឱសថការីមួយរូបទៀតជំនួស ។ បសុពេទ្យ ឬឱសថការីជំនួសមានការទទួលខុសត្រូវចំពោះមុខច្បាប់ដូចគ្នានឹងបសុពេទ្យ ឬឱសថការីទទួលខុសត្រូវដែរ ។ ការជំនួសអាចចូលជាធរមានបាន លុះត្រាតែមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។

**ប្រការ ១១** : ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ មានសិទ្ធិដកហូតវិញនូវលិខិតអនុញ្ញាតបើកគ្រឹះស្ថានផលិតបសុឱសថព្រមទាំងសាខា ក្នុងករណីពិនិត្យឃើញថា :

-សំណុំលិខិតមានលក្ខណៈក្លែងបន្លំ
-សាមីជនអនុវត្តមិនត្រឹមត្រូវតាមបែបបទនិងលក្ខខណ្ឌដូចបានកំណត់ក្នុងជំពូកទី២នៃប្រកាសរួមនេះ។

Downloaded from http://www.khmerlaws.com

**ប្រការ ១២ :** ការសុំបិទគ្រឹះស្ថានផលិតបសុឱសថ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្នុងរយៈពេលយ៉ាងតិច សាមសិប (៣០) ថ្ងៃ មុនពេលបិទជាក់ស្តែង ។

ការសុំប្តូរទីតាំងគ្រឹះស្ថានផលិតបសុឱសថ ត្រូវស្នើសុំការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដោយភ្ជាប់ជាមួយនូវ :

- លិខិតបញ្ជាក់លើទីតាំងធ្វើអាជីវកម្មថ្មី ចេញដោយអាជ្ញាធរដែនដី ចំនួន ០២ ច្បាប់
- គំនូសបំព្រួញ រូបថត ទីតាំង ចំនួន ០២ ច្បាប់
- គំនូសប្លង់នៃបន្ទប់ផលិតតាមខ្សែចង្វាក់ផលិតកម្ម ចំនួន ០២ ច្បាប់
- បញ្ជីរាយឈ្មោះសម្ភារៈ ឧបករណ៍ បម្រើការផលិត ចំនួន ០២ ច្បាប់ ។

## ជំពូក ទី ៣

## បែបបទ និង លក្ខខណ្ឌនៃការបើក បិទ ឬ ប្តូរទីតាំងគ្រឹះស្ថានអាហារ៍ណ នីហារ៍ណបសុឱសថ

**ប្រការ ១៣ :** រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលមានបំណង ឬ កំពុងបើកគ្រឹះស្ថានអាហារ៍ណ នីហារ៍ណបសុឱសថ ព្រមទាំងសាខា ត្រូវមានលិខិតអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

**ប្រការ ១៤ :** គ្រឹះស្ថានអាហារ៍ណ នីហារ៍ណបសុឱសថ ព្រមទាំងសាខាដែលបានទទួលការអនុញ្ញាតឱ្យបើកធ្វើអាជីវកម្មកន្លងមកអាចអនុញ្ញាតឱ្យបន្តអាជីវកម្មដដែល ប៉ុន្តែត្រូវមកបំពេញទម្រង់បែបបទបន្ថែមនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងត្រូវអនុវត្តតាមលក្ខខណ្ឌក្នុងប្រកាសរូមនេះ ។

**ប្រការ ១៥ :** រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលអាចមានសិទ្ធិបើកគ្រឹះស្ថានអាហារ៍ណ នីហារ៍ណបសុឱសថ ព្រមទាំងសាខា ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម :

- មានសញ្ជាតិខ្មែរ
- មានសញ្ញាប័ត្រជំនាញបសុព្យាបាល ដែលទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- មានទីលំនៅបច្ចុប្បន្ន ឬ ទីស្នាក់ការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ១៦ :** សំណុំលិខិតសុំបើកគ្រឹះស្ថានអាហារ៍ណ នីហារ៍ណបសុឱសថ មាន :

- ពាក្យសុំបើក មានបិទតែមប្រាំរយ (៥០០) រៀល (មានគំរូ) ចំនួន ០២ ច្បាប់
- បរិញ្ញាបត្របសុព្យាបាល ដែលទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ចំនួន ០២ ច្បាប់
- ប្រវត្តិរូបសង្ខេបមានបិទរូបថត ៤ x ៦ របស់អ្នកស្នើសុំ (មានគំរូ) ចំនួន ០២ ច្បាប់
- អត្តសញ្ញាណប័ណ្ណរបស់អ្នកស្នើសុំ (ថតចម្លង) ចំនួន ០២ ច្បាប់
- កិច្ចសន្យានៃការធ្វើអាជីវកម្ម (មានគំរូ) ចំនួន ០២ ច្បាប់
- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ចេញដោយក្រសួងពាណិជ្ជកម្ម ចំនួន ០២ ច្បាប់
- បញ្ជីដើម ពាណិជ្ជសញ្ញា សេវាសញ្ញា ពាណិជ្ជនាម ឬ លិខិតផ្ទេរសិទ្ធរបស់ក្រុមហ៊ុនផលិត (បើសិនជាមាន) ចំនួន ០២ ច្បាប់
- លិខិតបញ្ជាក់លើទីតាំងធ្វើអាជីវកម្មចេញដោយអាជ្ញាធរដែនដី ចំនួន ០២ ច្បាប់
- គំនូសបំព្រួញ រូបថតទីតាំង ចំនួន ០២ ច្បាប់ ។

Downloaded from http://www.khmerlaws.com

សាមីជនត្រូវមកទំនាក់ទំនងដើម្បីបំពេញសំណុំលិខិតខាងលើនៅក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

**ប្រការ ១៧ :** ការសុំបើកសាខានៃគ្រឹះស្ថានអាហារ៍ណ នីហារ៍ណបសុឱសថ ត្រូវអនុវត្តតាមបែបបទ និង លក្ខខណ្ឌដូចគ្នានឹងការសុំបើកគ្រឹះស្ថានអាហារ៍ណ នីហារ៍ណបសុឱសថដែរ ។

**ប្រការ ១៨ :** គ្រឹះស្ថានអាហារ៍ណ នីហារ៍ណបសុឱសថ ព្រមទាំងសាខា ត្រូវរៀបចំសមស្របតាមការកំណត់ ដូចខាងក្រោម :

-ទីចាត់ការត្រូវមានការរៀបចំតាមបែបផែនជាការិយាល័យ

-ត្រូវមានអនាម័យល្អទាំងក្នុង និង ក្រៅ ហើយត្រូវដាច់ចេញពីកន្លែងស្នាក់នៅ

-មានឃ្លាំងត្រូវដាច់ពីកន្លែងស្នាក់នៅ

-មានទូ និង កំណល់គ្រប់គ្រាន់សម្រាប់រៀបចំទុកដាក់ផលិតផលបសុឱសថ

-មានម៉ាស៊ីនត្រជាក់ និង កង្ហារគ្រប់គ្រាន់សម្រាប់រក្សាសីតុណ្ហភាពក្នុងឃ្លាំងតាមលក្ខណៈបច្ចេកទេស ។

**ប្រការ ១៩ :** លក្ខខណ្ឌនៃគ្រឹះស្ថានអាហារ៍ណ នីហារ៍ណបសុឱសថ ត្រូវៈ

១- ត្រូវមានបសុពេទ្យទទួលខុសត្រូវ គ្រប់គ្រងបច្ចេកទេសក្នុងគ្រឹះស្ថានរបស់ខ្លួន ។

២- ធានាចំពោះគុណភាព និង សុវត្ថិភាពបសុឱសថ របស់ខ្លួនដែលបានចែកចាយ ។

ក្នុងករណីមានការចោទប្រកាន់ពីក្រសួងមានសមត្ថកិច្ច គ្រឹះស្ថានត្រូវប្រមូលជាបន្ទាន់នូវបសុឱសថមិនត្រឹមត្រូវទាំងនោះមកវិញ ។

**ប្រការ ២០ :** ក្នុងករណីអវត្តមានបសុពេទ្យទទួលខុសត្រូវ គ្រឹះស្ថានអាហារ៍ណ នីហារ៍ណបសុឱសថ ព្រមទាំងសាខា ត្រូវមានបសុពេទ្យមួយរូបទៀតជំនួស ។ បសុពេទ្យជំនួសមានការទទួលខុសត្រូវចំពោះមុខច្បាប់ដូចគ្នានឹងបសុពេទ្យទទួលខុសត្រូវដែរ ។ ការជំនួសអាចចូលជាធរមានបាន លុះត្រាតែមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។

**ប្រការ ២១ :** ត្រូវបានហាមឃាត់ដាច់ខាតនូវសកម្មភាព អាហារ៍ណ នីហារ៍ណ ចែកចាយ ឬ ស្តុកទុក :

-បសុឱសថដែលគ្មានទិដ្ឋាការ ឬ បញ្ជិកា

-បសុឱសថដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ហាមឃាត់

-បសុឱសថក្លែងក្លាយ

- បសុឱសថខូចគុណភាព ឬ គ្មានគុណភាព

-បសុឱសថផុតកំណត់ពេលប្រើប្រាស់ ។

ហាមប្រកបអាជីវកម្មផ្សេងក្រៅពីបសុឱសថ នៅក្នុងគ្រឹះស្ថានអាហារ៍ណ នីហារ៍ណបសុឱសថព្រមទាំងសាខា។

ហាមចែកចាយបសុឱសថ ដល់គ្រឹះស្ថានលក់បសុឱសថ ណាដែលគ្មានលិខិតអនុញ្ញាតធ្វើអាជីវកម្មពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

**ប្រការ ២២:** ការសុំបិទគ្រឹះស្ថានអាហារ៍ណ នីហារ៍ណបសុឱសថ ព្រមទាំងសាខា ត្រូវជូនដំណឹងមកក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ នៅក្នុងរយៈពេលយ៉ាងតិច សាមសិប (៣០) ថ្ងៃ មុនពេលបិទជាក់ស្តែង ។

ការសុំប្តូរទីតាំងគ្រឹះស្ថានអាហារ៍ណ នីហារ៍ណបសុឱសថ ព្រមទាំងសាខា ត្រូវមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដោយភ្ជាប់ជាមួយនូវ :

-លិខិតបញ្ជាក់លើទីតាំងធ្វើអាជីវកម្មថ្មីចេញដោយអាជ្ញាធរដែនដី ចំនួន ០២ ច្បាប់

-គំនូសបំព្រួញ រូបថតទីតាំងថ្មី ចំនួន ០២ ច្បាប់ ។

Downloaded from http://www.khmerlaws.com

## ជំពូក ទី ៤

## ចែបបទ និង លក្ខខណ្ឌ ក្នុងការសុំបើក បិទ ឬ ប្តូរទីតាំងនៃគ្រឹះស្ថានលក់បសុឱសថ

**ប្រការ ២៣ :** ការបើកគ្រឹះស្ថានលក់បសុឱសថ ត្រូវមានលិខិតអនុញ្ញាតចេញដោយមន្ទីរកសិកម្មខេត្ត ក្រុង ។ បសុឱសថ ត្រូវមានប្រភពចេញពីគ្រឹះស្ថានអាហារីណ នីហរ័ណស្របច្បាប់ដែលទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ត្រូវមានទិដ្ឋាការ និង បញ្ជិកាត្រឹមត្រូវ ។

**ប្រការ ២៤ :** បុគ្គលដែលស្នើសុំបើកគ្រឹះស្ថានលក់បសុឱសថ ត្រូវមានលក្ខណៈសម្បត្តិ ដូចខាងក្រោម :

- មានសញ្ជាតិខ្មែរ
- មានសញ្ញាប័ត្រជំនាញបសុព្យាបាល ដែលទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

**ប្រការ ២៥ :** សំណុំលិខិតសុំបើកគ្រឹះស្ថានលក់បសុឱសថ មាន :

- ពាក្យសុំបើកមានបិទតែមប្រើតម្លៃប្រាំរយ (៥០០) រៀល (មានគំរូ) ចំនួន ០២ ច្បាប់
- មានបរិញ្ញាបត្របសុព្យាបាល ដែលទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ (ថតចម្លង) ចំនួន ០២ ច្បាប់
- ប្រវត្តិរូបសង្ខេបមានបិទរូបថត ៤ x ៦ របស់អ្នកស្នើសុំ (មានគំរូ) ចំនួន ០២ ច្បាប់
- អត្តសញ្ញាណប័ណ្ណរបស់អ្នកស្នើសុំ (ថតចម្លង) ចំនួន ០២ ច្បាប់ ។

សាមីជនត្រូវបំពេញសំណុំលិខិតខាងលើ ហើយបញ្ជូនមកមន្ទីរកសិកម្ម ខេត្ត ក្រុង ។

**ប្រការ ២៦ :** មន្ទីរកសិកម្ម ខេត្ត ក្រុង មានសិទ្ធិក្នុងការដកហូតវិញ នូវលិខិតអនុញ្ញាតបើកគ្រឹះស្ថានបសុឱសថក្នុងករណីពិនិត្យឃើញថា :

- សំណុំលិខិតមានលក្ខណៈក្លែងបន្លំ
- សាមីជនរៀបចំគ្រឹះស្ថានលក់បសុឱសថ មិនសមស្របតាមលក្ខខណ្ឌកំណត់
- លក់បសុឱសថក្លែងក្លាយ ឬ គ្មានគុណភាព ឬ ខូចគុណភាព
- លក់បសុឱសថផុតកំណត់ប្រើប្រាស់ ចែកចាយ ឬ លក់បសុឱសថយកទៅព្យាបាលមនុស្ស ។

**ប្រការ ២៧ :** ការបើកគ្រឹះស្ថានលក់បសុឱសថ ត្រូវរៀបចំឱ្យបានសមស្របតាមការកំណត់ ដូចខាងក្រោម:

- ត្រូវស្ថិតនៅដាច់ចេញពីកន្លែងស្នាក់នៅ និង មានអនាម័យល្អ
- ត្រូវមានផ្លាកយីហោគ្រឹះស្ថានលក់បសុឱសថ
- មានទូកញ្ចក់សមស្របសម្រាប់ដាក់តាំងបសុឱសថ និង សម្ភារៈបរិក្ខារបសុពេទ្យ
- មានទូទឹកកកឬបន្ទប់ត្រជាក់សម្រាប់ទុកដាក់បសុឱសថ ដែលទាមទារការរក្សាទុកក្នុងសីតុណ្ហភាពកំណត់ ។

**ប្រការ ២៨ :** ការសុំបិទគ្រឹះស្ថានលក់បសុឱសថ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកមន្ទីរកសិកម្មខេត្ត ក្រុង ក្នុងរយៈពេលយ៉ាងតិច ដប់ប្រាំ (១៥) ថ្ងៃ មុនពេលបិទជាក់ស្តែង ។

ការសុំប្តូរទីតាំងគ្រឹះស្ថានលក់បសុឱសថ ត្រូវស្នើសុំការអនុញ្ញាតពីមន្ទីរកសិកម្មខេត្ត ក្រុង ។



Downloaded from http://www.khmerlaws.com

## ជំពូកទី ៥

## ទំរង់ និង លក្ខខណ្ឌនៃការចុះទិដ្ឋាការ ឬ បញ្ជិកាបសុឱសថ

**ប្រការ ២៩ :** រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលបាន និង កំពុង ឬ មានបំណងផលិត អាហារណ៍ នីហារណ៍ ចែកចាយ ឬ លក់ដូរបសុឱសថមុខណាមួយ ត្រូវចុះទិដ្ឋាការ និង បញ្ជិកានៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

ទិដ្ឋាការ និង បញ្ជិកាបសុឱសថមានសុពលភាពរយៈពេលប្រាំ(០៥)ឆ្នាំគិតចាប់ពីថ្ងៃចេញទិដ្ឋាការ និង បញ្ជិកាបសុឱសថប្រសិនបើគ្មានការដកហូត ឬ លុបចោលណាមួយ ។

ការស្នើសុំចុះទិដ្ឋាការបសុឱសថមួយមុខ១ ត្រូវបំពេញសំណុំលិខិត ដូចខាងក្រោម :

- ពាក្យសុំមានបិទតែមប្រឹតថ្លៃប្រាំរយ (៥០០) រៀល (មានគំរូ) ចំនួន ០២ ច្បាប់
- លិខិតអនុញ្ញាតធ្វើអាជីវកម្ម ចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ (ថតចម្លង) ចំនួន ០២ ច្បាប់
- ព័តិមានបច្ចេកទេសស្តីពីផលិតផល ចំនួន ០២ ច្បាប់
- វិញ្ញាបនបត្របញ្ជាក់ពីគុណភាព គ្រប់គ្រងផលិតកម្មរោងចក្រ តាមលក្ខខណ្ឌ កំណត់ដោយអង្គការសុខភាពពិភពលោក ចំនួន ០២ ច្បាប់
- គំរូសម្ភារៈវេចខ្ចប់ និង ស្លាកសញ្ញាអក្សរខ្មែរ ចំនួន ០២ ច្បាប់
- គំរូបសុឱសថ ចំនួន ០២ ឯកតា ។

រាល់ឯកសារបច្ចេកទេសខាងលើត្រូវសរសេរ ឬ បកប្រែជាភាសាខ្មែរជាចាំបាច់ ។

ការស្នើសុំចុះបញ្ជិកាបសុឱសថមួយមុខ១ ត្រូវបំពេញសំណុំលិខិត ដូចខាងក្រោម :

- ពាក្យសុំមានបិទតែមប្រឹតថ្លៃប្រាំរយ (៥០០) រៀល (មានគំរូ) ចំនួន ០២ ច្បាប់
- លិខិតអនុញ្ញាតធ្វើអាជីវកម្មបសុឱសថ ចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ (ថតចម្លង) ចំនួន ០២ ច្បាប់
- វិញ្ញាបនបត្រអនុញ្ញាតឱ្យធ្វើពាណិជ្ជកម្មលើទីផ្សារក្នុងប្រទេសផលិត ឬ វិញ្ញាបនបត្រ ចុះបញ្ជិកាក្នុងប្រទេសផលិត ឬ នាំចេញ ចំនួន ០២ ច្បាប់
- ព័តិមានបច្ចេកទេសស្តីពីផលិតផល ចំនួន ០២ ច្បាប់
- គំរូសម្ភារៈវេចខ្ចប់ និង ស្លាកសញ្ញាអក្សរខ្មែរ ចំនួន ០២ ច្បាប់
- គំរូបសុឱសថ ចំនួន ០២ ឯកតា ។

រាល់ឯកសារបច្ចេកទេសខាងលើត្រូវសរសេរ ឬ បកប្រែជាភាសាខ្មែរជាចាំបាច់ ។

**ប្រការ ៣០ :** ក្នុងរយៈពេលបី (៣) ខែមុនពេលផុតកំណត់នៃទិដ្ឋាការ និង បញ្ជិកានៃបសុឱសថ សាមីអាជីវករ ត្រូវដាក់ពាក្យសុំបន្តសុពលភាពទិដ្ឋាការ និង បញ្ជិកានូវប្រភេទបសុឱសថនោះជាថ្មីនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយបំពេញសំណុំលិខិតដូចខាងក្រោម :

- ពាក្យសុំមានបិទតែមប្រឹតថ្លៃប្រាំរយ (៥០០) រៀល (មានគំរូ) ចំនួន ០២ ច្បាប់
- លិខិតអនុញ្ញាតធ្វើអាជីវកម្ម ចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ (ថតចម្លង) ចំនួន ០២ ច្បាប់
- ទិដ្ឋាការ ឬ បញ្ជិកាចាស់ (ថតចម្លង) ចំនួន ០២ ច្បាប់ ។

Downloaded from http://www.khmerlaws.com

**ប្រការ ៣១ :** ការវិភាគបសុឱសថ ត្រូវធ្វើឡើងនៅមន្ទីរពិសោធន៍ដែលទទួលស្គាល់ដោយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។ រាល់ការចំណាយ លើការវិភាគជាបន្ទុករបស់អ្នកស្នើសុំ ។

**ប្រការ ៣២ :** ក្នុងករណីចាំបាច់ សាមីជនត្រូវផ្តល់បន្ថែមនូវឯកសារ ឬ អង្គធាតុប្រតិករសម្រាប់ការវិភាគតាមសំណើរបស់នាយកដ្ឋាននីតិកម្មកសិកម្ម ឬ មន្ទីរពិសោធន៍ដែលទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

**ប្រការ ៣៣ :** បសុឱសថសម្រាប់ការសិក្សាស្រាវជ្រាវក្នុងវិស័យបសុព្យាបាលរបស់រដ្ឋដែលមិនបម្រើឱ្យការធ្វើអាជីវកម្ម ហើយដែលមានច្បាប់អនុញ្ញាតនាំចូលពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ហើយនោះ មិនតម្រូវឱ្យចុះបញ្ជិកាទេ ។

**ប្រការ ៣៤ :** ទោះជាមានឈ្មោះដូចគ្នាក្តី បសុឱសថដែលមានកម្រិតសមាសភាគខុសគ្នា រូបលក្ខណៈខុសគ្នា ឬរោងចក្រផលិតខុសគ្នា ត្រូវសុំចុះទិដ្ឋាការ និង បញ្ជិកាបសុឱសថផ្សេងគ្នា ។

**ប្រការ ៣៥ :** មុនដំណើរការផ្លាស់ប្តូរសមាសធាតុរួមផ្សំ ទម្រង់បង្ហាញ រូបភាពវេចខ្ចប់ ផ្លូវប្រើប្រាស់ វិធីប្រើប្រាស់ គុណភាពប្រើប្រាស់ ឬ ឈ្មោះពាណិជ្ជកម្មនៃប្រភេទបសុឱសថមុខណាមួយនោះ សាមីម្ចាស់បសុឱសថចាំបាច់ត្រូវស្នើសុំការឯកភាពពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ជាមុនសិន ទើបអាចអនុញ្ញាតឱ្យធ្វើចរាចរចែកចាយ និង លក់ដូរបាន ។

**ប្រការ ៣៦ :** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ មានសិទ្ធិជំទាស់ការសុំចុះទិដ្ឋាការ ឬ បញ្ជិកាចំពោះបសុឱសថទាំងឡាយណាដែលក្រសួងពិនិត្យឃើញថា :

-មានសារៈសំខាន់តិចតួច ឬ គ្មានសារៈសំខាន់ក្នុងការបង្ការ ឬ ព្យាបាលជំងឺសត្វ ឬ អាចមានគ្រោះថ្នាក់ដល់សុខភាពសត្វ

-មានឯកសារបច្ចេកទេសមិនត្រឹមត្រូវ ឬ ក្លែងបន្លំ

-ប្រទេសផលិតបានចេញលិខិតហាមឃាត់ការប្រើប្រាស់នៅក្នុងប្រទេសផលិត ។

**ប្រការ ៣៧ :** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ មានសិទ្ធិព្យួរទុក ឬ ដកហូតទិដ្ឋាការ ឬ បញ្ជិកា ចំពោះបសុឱសថទាំងឡាយណាដែលក្រសួងពិនិត្យឃើញថា :

-មានគ្រោះថ្នាក់ដល់សុខភាពសត្វ

-មានការចោទប្រកាន់អំពីគុណភាពពីក្រសួងមានសមត្ថកិច្ចក្នុង ឬ ក្រៅប្រទេស

-មានការហាមឃាត់ការប្រើប្រាស់ពីប្រទេសផលិត

-មានឯកសារគំរូមិនត្រឹមត្រូវ ឬ ក្លែងបន្លំ ។

**ប្រការ ៣៨ :** នៅក្នុងគ្រឹះស្ថានធ្វើអាជីវកម្មបសុឱសថ ត្រូវដាក់បង្ហាញឱ្យឃើញនូវលិខិតអនុញ្ញាតធ្វើអាជីវកម្ម ចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ត្រូវមានទិដ្ឋាការ ឬ បញ្ជិកា ឬ លិខិតថតចម្លងទិដ្ឋាការបញ្ជិកាបសុឱសថគ្រប់មុខ ដែលកំពុងធ្វើអាជីវកម្មក្នុងគ្រឹះស្ថាននោះ ។

**ប្រការ ៣៩ :** សម្ភារៈវេចខ្ចប់បសុឱសថទាំងអស់ត្រូវមានស្លាកសញ្ញាជាភាសាខ្មែរ ផ្តល់ព័ត៌មានគ្រប់គ្រាន់ច្បាស់លាស់ និង ងាយយល់សម្រាប់អ្នកប្រើប្រាស់សមស្របតាមការណែនាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ជាអាទិ៍ត្រូវមាន :

-ឈ្មោះពាណិជ្ជកម្ម

Downloaded from http://www.khmerlaws.com

-ឈ្មោះសាកល
-សមាសភាគនៃសារជាតិសកម្ម និង សមាសធាតុរួមផ្សំ
-ប្រសិទ្ធភាពនៃបសុឱសថ
-របៀប និង កម្រិតប្រើ
-ឈ្មោះ និង អាសយដ្ឋានរោងចក្រផលិត
-ឈ្មោះ និង អាសយដ្ឋានអ្នកនាំចូល
-លេខទិដ្ឋាការ ឬ បញ្ជិកាបសុឱសថ ចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
-ថ្ងៃ ខែ ឆ្នាំផលិត និង ផុតកំណត់ប្រើប្រាស់
-លេខឡូត៍ ។

## ជំពូកទី ៦

## អាហរណ និហរណកម្មបសុឱសថ

**ប្រការ ៤០ :** អាចទទួលនូវលិខិតអនុញ្ញាតឱ្យធ្វើការនាំចូល នាំចេញបសុឱសថមុខណាមួយបាន លុះណាតែរូបវន្តបុគ្គល ឬ នីតិបុគ្គលនោះបានទទួលលិខិតអនុញ្ញាតធ្វើអាជីវកម្មបសុឱសថ ហើយបសុឱសថទាំងនោះត្រូវបានទទួលចុះទិដ្ឋាការ ឬ បញ្ជិកាត្រឹមត្រូវរួចហើយពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

**ប្រការ ៤១ :** សំណុំលិខិតស្នើសុំលិខិតអនុញ្ញាតនាំចូល នាំចេញមាន :

-ពាក្យសុំមានបិទតែមប្រិ៍តម្លៃប្រាំរយ ( ៥០០ ) រៀល ( មានគំរូ ) ចំនួន ០២ ច្បាប់
-លិខិតអនុញ្ញាតធ្វើអាជីវកម្មបសុឱសថ ចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ( ថតចម្លង ) ចំនួន ០២ ច្បាប់
-វិញ្ញាបនបត្រចុះទិដ្ឋាការ ឬ បញ្ជិកា ( ថតចម្លង ) ចំនួន ០២ ច្បាប់
-កិច្ចសន្យាស្តីពីការនាំចូល នាំចេញបសុឱសថ ( មានគំរូ) ចំនួន ០២ ច្បាប់ ។

**ប្រការ ៤២ :** លិខិតអនុញ្ញាតឱ្យនាំចូល នាំចេញបសុឱសថមានសុពលភាពរយៈពេលមួយ (០១) ឆ្នាំ ដោយគិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាតនោះ ។

**ប្រការ ៤៣ :** បសុឱសថដែលអនុញ្ញាតឱ្យនាំចូលបាន ត្រូវមានរយៈពេលអាចប្រើប្រាស់បន្តយ៉ាងតិចដប់ប្រាំបី (១៨) ខែ មុនថ្ងៃផុតកំណត់ការប្រើប្រាស់ បន្ទាប់ពីមកដល់ព្រះរាជាណាចក្រកម្ពុជា ។

បសុឱសថដែលនាំចូល ត្រូវមានទម្រង់បង្ហាញ និង មានស្តង់ដាគុណភាពត្រឹមត្រូវតាមគំរូបសុឱសថដែលបានទទួលការអនុញ្ញាតចុះបញ្ជិកាពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រួចហើយ ។

**ប្រការ ៤៤ :** រាល់ពេលនាំចូលបសុឱសថមកដល់ឃ្លាំងស្តុក ម្ចាស់ផលិតផលនាំចូល ត្រូវរាយការណ៍ជាលាយលក្ខអក្សរជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដើម្បីចាត់មន្ត្រីជំនាញចុះត្រួតពិនិត្យ ។

Downloaded from http://www.khmerlaws.com

## ជំពូកទី ៧

## ការផ្សព្វផ្សាយពាណិជ្ជកម្មបសុឱសថ

**ប្រការ ៤៥ :** រាល់ការផ្សព្វផ្សាយបសុឱសថគ្រប់ប្រភេទ ទោះតាមមធ្យោបាយណាក៏ដោយ ត្រូវមានការអនុញ្ញាតពី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។ រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលបានចុះទិដ្ឋាការ ឬ បញ្ជិកា បសុឱសថណាមួយរួចហើយ ហើយមានបំណងផ្សាយពាណិជ្ជកម្មបសុឱសថនោះត្រូវដាក់នូវអត្ថបទ ឬ / និង រូបភាពបញ្ចាំង ឬ រូបភាពបសុឱសថប្រភេទទាំងនោះជូនមកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដើម្បីពិនិត្យ និង សម្រេចឯកភាពជាមុន មុននឹងធ្វើការផ្សព្វផ្សាយ ។

**ប្រការ ៤៦ :** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ មានសិទ្ធិផ្អាកភ្លាមជាបណ្តោះអាសន្ននូវការផ្សព្វផ្សាយបសុឱសថ ដែលគ្មានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។

## ជំពូកទី ៨

## ភារកិច្ចរបស់អាជីវករ

**ប្រការ ៤៧ :** អាជីវករដែលធ្វើអាជីវកម្មបសុឱសថត្រូវ :

-គោរពឱ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិ និង សេចក្តីណែនាំផ្សេងៗរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-បង្កលក្ខណៈងាយស្រួលដល់គ្រប់សកម្មភាពត្រួតពិនិត្យរបស់មន្ត្រីជំនាញក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង មន្ទីរកសិកម្មខេត្ត ក្រុង

-មានសៀវភៅកត់ត្រាស្ថិតិបសុឱសថចេញ ចូល និង ស្តុកជាប្រចាំ

-ត្រូវចុះឈ្មោះបសុឱសថដែលលក់ជូនអតិថិជនក្នុងសៀវភៅលក់ប្រចាំថ្ងៃ ។

## ជំពូកទី ៩

## សមត្ថកិច្ចគ្រប់គ្រង

**ប្រការ ៤៨ :** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ មានសមត្ថកិច្ចទូទៅក្នុងការគ្រប់គ្រង ត្រួតពិនិត្យ ណែនាំ រាល់ការធ្វើអាជីវកម្មបសុឱសថគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

មន្ត្រីនគរបាលយុត្តិធម៌នៃនាយកដ្ឋាននីតិកម្មកសិកម្ម និង មន្ទីរកសិកម្ម ខេត្ត ក្រុងមានតួនាទី និង សិទ្ធិ ដូចខាងក្រោម :

-ស្រាវជ្រាវទប់ស្កាត់ និង បង្ក្រាបបទល្មើសបមាណិគុណភាពសម្ភារៈកសិកម្មក្នុងការធ្វើអាជីវកម្មបសុ ឱសថទូទៅក្នុងដែនសមត្ថកិច្ចរៀងៗខ្លួន និង ដោះស្រាយបទល្មើសស្របតាមនីតិវិធី

-ចូលត្រួតពិនិត្យក្នុងគ្រឹះស្ថាន និង បរិវេណគ្រឹះស្ថាន ឃ្លាំងស្តុក យានយន្តដឹកជញ្ជូន តំសិដ្ឋាន និង កន្លែងដែលពាក់ព័ន្ធនឹងការធ្វើអាជីវកម្មបសុឱសថ ដែលសង្ស័យថាបានបំពានលើខ្លឹមសារច្បាប់ ស្តីពីគ្រប់គ្រងឱសថ និង អនុក្រឹត្យលេខ ៦៩ អនក្រ.បក ស្តីពីបមាណី និង ការគ្រប់គ្រងសម្ភារៈកសិកម្ម

Downloaded from http://www.khmerlaws.com

រួមទាំងប្រកាសរួមនេះ

-តម្រូវឱ្យអាជីវករបង្ហាញសៀវភៅកត់ត្រាស្ថិតិចេញ ចូល និង ស្តុក ឬ ឯកសារផ្សេងៗដែលពាក់ព័ន្ធនឹងការធ្វើអាជីវកម្មបសុឱសថ

-យកគំរូនៃផលិតផលបសុឱសថទាំងឡាយណាដែលសង្ស័យថាមិនមានបមាណីគុណភាពត្រឹមត្រូវ ដើម្បីធ្វើការពិសោធផ្ទៀងផ្ទាត់

-ឃាត់ទុកវត្ថុតាងល្មើសច្បាប់ជាបណ្តោះអាសន្ន ចងក្រងសំណុំរឿងនៃបទល្មើសស្របតាមនីតិវិធី

-ពិនិត្យផ្ទៀងផ្ទាត់សំណុំឯកសារធ្វើអាជីវកម្ម ផលិត អាហរ័ណ នីហរ័ណ ស្តុក វេចខ្ចប់ ចែកចាយ និង លក់ដូរផលិតផលបសុឱសថ ។

## ជំពូកទី ១០

## ទោសប្បញ្ញត្តិ

**ប្រការ ៤៩ :** ត្រូវផ្តន្ទាទោសស្របតាមមាត្រា ១០ នៃច្បាប់ស្តីពីការគ្រប់គ្រងឱសថ ចំពោះរូបវន្តបុគ្គល ឬ នីតិបុគ្គលណាដែលប្រព្រឹត្តល្មើស ដូចខាងក្រោម :

១-ផ្សព្វផ្សាយបសុឱសថដែលគ្មានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

២-ប្រព្រឹត្តល្មើសនឹងបែបបទ ឬ លក្ខខណ្ឌផលិតកម្ម អាហរ័ណ នីហរ័ណកម្ម និង ពាណិជ្ជកម្មបសុឱសថ ។

៣-បើក ឬ ប្តូរទីតាំងគ្រឹះស្ថានលក់បសុឱសថ គ្រឹះស្ថានផលិតបសុឱសថ ឬ ធ្វើអាជីវកម្មអាហរ័ណ នីហរ័ណកម្មបសុឱសថ ដោយគ្មានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

៤-ផលិត នាំចូល នាំចេញ ស្តុកបសុឱសថ វត្ថុធាតុដើមបសុឱសថ ដោយគ្មានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

៥-លក់បសុឱសថគ្មានទិដ្ឋាការ និង បញ្ជិកា ឬ បសុឱសថ ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទបានហាមឃាត់ ។

**ប្រការ ៥០ :** ត្រូវផ្តន្ទាទោសស្របតាមមាត្រា ១១ នៃច្បាប់ស្តីពីការគ្រប់គ្រងឱសថ ចំពោះជនណាដែលរារាំងមិនឱ្យមន្ត្រីមានសមត្ថកិច្ច ដូចមានចែងក្នុងប្រការ ៤៨ បំពេញភារកិច្ចអនុវត្តច្បាប់របស់ខ្លួន ។

**ប្រការ ៥១ :** ត្រូវផ្តន្ទាទោសស្របតាមមាត្រា ១២ នៃច្បាប់ស្តីពីការគ្រប់គ្រងឱសថ ចំពោះជនណាដែលធ្វើផលិតកម្ម អាហរ័ណ នីហរ័ណកម្ម និង ពាណិជ្ជកម្មដោយចេតនា នូវបសុឱសថក្លែងក្លាយ បសុឱសថគ្មានគុណភាព បសុឱសថហួសរយៈពេលប្រើប្រាស់ ដែលធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពសត្វ ឬ បង្កហានិភ័យដល់សុវត្ថិ ភាពស្បៀង ។

Downloaded from http://www.khmerlaws.com

## ជំពូកទី ១១

## អវសានប្បញ្ញត្តិ

**ប្រការ ៥២ :** ប្រកាស ឬ សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសរួមនេះត្រូវទុកជានិរាករណ៍។

**ប្រការ ៥៣ :** អគ្គនាយក អគ្គាធិការ នាយកខុទ្ទកាល័យនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានផលិតកម្ម និង បសុពេទ្យាបាល ប្រធានមន្ទីរកសិកម្មខេត្ត ក្រុង ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះតាមភារកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០៧

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត់-ជុំ

(ត្រា និងហត្ថលេខា)

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ចាន់-សារុន

(ត្រា និងហត្ថលេខា)

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត ក្រុង
- ដូចប្រការ៥៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

Downloaded from http://www.khmerlaws.com